# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ដីចំនួន ៦៨០ ហិកតា
## ស្ថិតនៅសង្កាត់អូរត្រេះ ខណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស /រកម/០១៩៦ /០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពីការប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/០៨០៦/៣៣៧ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និង បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និង នីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ
- យោងលិខិតលេខ ២៨៨ សជណ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៨ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងលិខិតលេខ ៣៩៥ សជណ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៨ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងលិខិតលេខ ៤៧ សណ/០៨ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៨ របស់សាលាក្រុងព្រះសីហនុ

## សម្រេច

**មាត្រា ១.-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីសមុទ្រចំនួន ៦៨០ ហិកតា ស្ថិតនៅ

ក្នុងសង្កាត់អូរត្រេះ ខណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ តាមនិយាមការដែលបានកំណត់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់។

**មាត្រា ២.-**

ផ្ទៃដីដែលធ្វើអនុបយោគខាងលើនេះ ត្រូវស្ថិតក្រោមការចាត់ចែង និង បំពេញនីតិវិធីអនុវត្ត ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ក្រសួងសាធារណការ និង ដឹកជញ្ជូន ក្រសួងបរិស្ថាន ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួង ស្ថាប័នមានការពាក់ព័ន្ធ និង សាលាក្រុងព្រះសីហនុ ដោយសហការជាមួយក្រុមហ៊ុន Cambodia International Investment Development Group Co.,Ltd ស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល ចែងក្នុងលិខិតលេខ ៣៥៥ សជណ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៨ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី។

**មាត្រា ៣.-**

ត្រូវបានផ្ដល់ជូនក្រុមហ៊ុន Cambodia International Investment Development Group Co.,Ltd នូវផ្ទៃដីចំនួន ៥៣០.៤០ "ប្រាំរយសាមសិប ហិកតា និង សែសិប អា" ដើម្បីអភិវឌ្ឍន៍ជាកំពង់ផែអន្តរជាតិ។ ផ្ទៃដីទំហំ ១៤៩.៦០ "មួយរយសែសិបប្រាំបួន ហិកតា និង ហុកសិប អា" ដែលជាចំណែករបស់រដ្ឋ ត្រូវកត់ត្រាទៅក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ របស់សាលាក្រុងព្រះសីហនុ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង អភិបាលក្រុងព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០០៨

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- ដូចមាត្រា ៥
- ឯកសារ-កាលប្បវត្តិ